មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេប
# ការរឹតត្បិតប្រព័ន្ធផ្សព្វផ្សាយ និងបទពិសោធន៍របស់អ្នកសារព័ត៌មានក្នុងការរាយការណ៍ព័ត៌មានអំពីជម្លោះព្រំដែនកម្ពុជា-ថៃ

## សេចក្តីផ្តើម

ផលជះនៃការធ្លាក់ចុះសេរីភាពសារព័ត៌មាននៅកម្ពុជាដែលបានកើតឡើងអស់រយៈពេលជាច្រើនឆ្នាំកន្លងមក បានបង្ហាញកាន់តែច្បាស់ជាពិសេសក្នុងអំឡុងពេលជម្លោះព្រំដែនរវាងកម្ពុជានិងថៃ។ ជម្លោះប្រដាប់អាវុធដែលបានកើតឡើងចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៨ ខែកក្កដា មុនពេលបទឈប់បាញ់រវាងប្រទេសទាំងពីរចូលជាធរមាន ភាពតានតឹងនិងការប៉ះទង្គិចនៅតែបន្តកើតមាននៅតាមបណ្តោយព្រំដែនជាបន្តបន្ទាប់ ដោយមានការបាញ់ផ្លោងនៅចុងខែកញ្ញា មុនពេលដែលមេដឹកនាំប្រទេសទាំងពីរចុះកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងកូឡាឡាំពួ កាលពីថ្ងៃទី២៨ ខែតុលា និងហេតុការណ៍បាញ់ប្រហារ និងឧប្បត្តិហេតុគ្រាប់មីនដែលបានកើតឡើងនៅពាក់កណ្តាលខែវិច្ឆិកា។ បរិយាកាសរឹតត្បិតនិងអរិភាពសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនៅកម្ពុជាមិនត្រឹមតែបន្តកើតមានឡើងក្នុងអំឡុងជម្លោះនិងភាពតានតឹងប៉ុណ្ណោះទេ ថែមទាំងនៅមានករណីរឹតត្បិតជាច្រើនទៀតបានកើតឡើងតាមមធ្យោបាយផ្សេងៗ ជាពិសេសការទទួលព័ត៌មានដែលអាចទុកចិត្តបាន មិនត្រឹមតែជាផលប្រយោជន៍សាធារណៈប៉ុណ្ណោះទេ ថែមទាំងក៏ជាមធ្យោបាយសម្រាប់ជនស៊ីវិលក្នុងការទទួលព័ត៌មានដើម្បីធ្វើការសម្រេចចិត្តអំពីសុវត្ថិភាព និងសន្តិសុខផ្ទាល់ខ្លួន។ អ្នកសារព័ត៌មានជាតិនិងអ្នកសារព័ត៌មានបរទេសដែលយកព័ត៌មានឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអន្តរជាតិត្រូវបានឃុំខ្លួន ខណៈអ្នកខ្លះទៀតត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទញុះញង់ បទប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលអាចអ្វីឱ្យអន្តរាយការការពារជាតិ និងចារកម្ម ហើយប្រព័ន្ធផ្សព្វផ្សាយមួយត្រូវបានដកហូតអាជ្ញាប័ណ្ណ។ កំណត់ត្រាសង្ខេបនេះបង្ហាញពីហេតុការណ៍មួយចំនួន ទស្សនៈរបស់អ្នកសារព័ត៌មានដែលបានរាយការណ៍អំពីជម្លោះ តាមរយៈការសម្ភាសជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") និងចុងក្រោយការផ្តល់អនុសាសន៍ទៅកាន់រដ្ឋាភិបាល។

ម.ស.ម.ក បានសម្ភាសអ្នកសារព័ត៌មានចំនួន២៤នាក់ ដែលបានចុះយកព័ត៌មានផ្ទាល់អំពីជម្លោះព្រំដែននេះ ទាំងប្រព័ន្ធផ្សព្វផ្សាយជាតិ និងអន្តរជាតិ ដែលអ្នកខ្លះជាអ្នកសារព័ត៌មានដែលគ្មានអង្គភាព ចំណែកអ្នកខ្លះទៀតជាបុគ្គលិកនៃប្រព័ន្ធផ្សព្វផ្សាយទាំងនោះផ្ទាល់។ ម.ស.ម.ក ក៏បានស្នើសុំសម្ភាសន៍បុគ្គលិក ឬម្ចាស់នៃប្រព័ន្ធផ្សព្វផ្សាយមួយចំនួនដែលមាននិន្នាការទៅនឹងរាជរដ្ឋាភិបាលផងដែរ។ តែគួរឱ្យសោកស្តាយ យើងខ្ញុំ

មិនបានទទួលកិច្ចសហការក្នុងការផ្តល់បទសម្ភាសពីប្រព័ន្ធផ្សព្វផ្សាយទាំងនោះ ក្នុងពេលវេលាគ្រប់គ្រាន់មុនពេលការចេញផ្សាយកំណត់ត្រាសង្ខេបនេះទេ។

## ហេតុការណ៍នៃការរឹតត្បិតប្រព័ន្ធផ្សព្វផ្សាយដែលគួរឱ្យកត់សម្គាល់

នៅក្នុងបរិបទនៃជម្លោះ មានហេតុការណ៍នៃសេរីភាពប្រព័ន្ធផ្សព្វផ្សាយរហូតមកដល់បច្ចុប្បន្នសំខាន់ៗជាច្រើនត្រូវបានរឹតត្បិតនិងបង្កការរំខាន។ ភាគច្រើននៃហេតុការណ៍ទាំងនេះ បានដៅទៅលើអ្នកសារព័ត៌មាន ហើយបានជះឥទ្ធិពលយ៉ាងខ្លាំងលើអ្នកសារព័ត៌មាន និងលំហប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផ្សេងៗជាច្រើន។ គួរឱ្យកត់សម្គាល់ផងដែរថាផលជះបែបនេះគឺកំពុងកើតឡើងនៅក្នុងបរិយាកាសដែលការគ្រប់គ្រងនិងការដាក់សម្ពាធរបស់រាជរដ្ឋាភិបាលទៅលើប្រព័ន្ធផ្សព្វផ្សាយដែលមានភាពរឹតត្បិតរួចមកហើយ។

### *ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥*

អ្នកសារព័ត៌មាន ចំនួន៩នាក់ ក្នុងនោះមាន ០៧នាក់ មកពីស្ថាប័នសារព័ត៌មានក្នុងស្រុក និងពីរ នាក់ទៀតជាអ្នករាយការណ៍ឱ្យសារព័ត៌មានអន្តរជាតិ ដែលមានអ្នកសារព័ត៌មានបរទេសម្នាក់ ត្រូវបានឃាត់ខ្លួននៅទីតាំងត្រួតពិនិត្យរបស់នគរបាលក្រុងសំរោង ហើយបាននាំទៅកាន់ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យដើម្បីសាកសួរ។

ទាក់ទិននឹងអ្នកទាំង៧នាក់ដែលរាយការណ៍ឱ្យប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក មុនពេលឃាត់ខ្លួននគរបាលបានសុំមើលកាមេរ៉ា និងទូរស័ព្ទហើយសួរថាបានថតរូបអ្វីខ្លះ។ នគរបាលបានណែនាំឱ្យបិទទូរស័ព្ទ និងកាមេរ៉ាដោយសារតែហានិភ័យនៃការចាប់យកទីតាំងតាមប្រព័ន្ធGPS ។ ពេលមកដល់ស្នងការដ្ឋាន នគរបាលស្នងការរងខេត្តបានបញ្ជាឱ្យសួរចម្លើយម្តងមួយៗ។ មុននឹងត្រូវដោះលែង នគរបាលបានព្រមានអ្នកសារព័ត៌មានថាមិនត្រូវទៅជិតព្រំដែន ឬថតរូបមូលដ្ឋានយោធានោះទេ។

នៅក្នុងហេតុការណ៍ដាច់ដោយឡែកមួយនៅថ្ងៃដដែលនោះ មិនយូរប៉ុន្មានបន្ទាប់ពីអ្នកទាំង០៧នាក់ត្រូវបានឃាត់ខ្លួន អ្នកសារព័ត៌មានខ្មែរម្នាក់ និងអ្នកសារព័ត៌មានបរទេសម្នាក់ដែលរាយការណ៍ឱ្យសារព័ត៌មានអន្តរជាតិក៏ត្រូវបានឃាត់ខ្លួននៅក្រុងសំរោង។ នគរបាលបានប្រាប់អ្នកសារព័ត៌មាននោះឱ្យប្រគល់ទូរស័ព្ទពួកគេដោយសារតែហានិភ័យនៃការចាប់យកទីតាំងតាមប្រព័ន្ធGPS ទោះបីជាប្រព័ន្ធផ្សព្វផ្សាយដែលមានទំនោរទៅរាជរដ្ឋាភិបាលកំពុងផ្សាយពីតំបន់តែមួយនោះក៏ដោយ។ អ្នករាយការណ៍ព័ត៌មានពីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យនេះក៏ព្យាយាមសម្ភាសអ្នកសារព័ត៌មានម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានផ្សេងៗទៀតដែរ ហើយនគរបាលខេត្តបានថតរូបនិងរថយន្តរបស់ពួកគេ។ បន្ទាប់មក នគរបាលខេត្តបាននាំខ្លួនពួកគាត់ទៅកាន់ការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់នៃស្នងការដ្ឋាននគរបាលខេត្ត ប៉ុន្តែមិនបានបង្ហាញថាមានបទល្មើសអ្វីដែលអ្នកសារព័ត៌មានត្រូវបានចោទប្រកាន់នោះទេ។ នគរបាលបានថតលិខិតឆ្លងដែនរបស់អ្នកសារព័ត៌មាន ហើយបានសួរថាតើពួកគេបានទៅទីណានិងបាននិយាយជាមួយអ្នកណា។ នគរបាលបានត្រួតពិនិត្យឧបករណ៍របស់ពួកគេ និងរូបថត ហើយបានពិនិត្យសារនៅលើទូរស័ព្ទរបស់ពួកគេ អ្វីដែលគួរឱ្យកត់សម្គាល់មិនបានឆែកកុំព្យូទ័រ ឬកាមេរ៉ារបស់ពួកគេនោះទេ។ នគរបាលបានសន្និដ្ឋានថាអ្នកសារព័ត៌មានអាចជាអ្នកស៊ើបការណ៍។ បន្ទាប់មក នគរបាលបានធ្វើ

របាយការណ៍ដើម្បីឱ្យអ្នកសារព័ត៌មានចុះហត្ថលេខា ប៉ុន្តែដំបូងឡើយពួកគេបានបដិសេធ ដោយសារផ្នែក "បទល្មើសដែលបានប្រព្រឹត្ត" ត្រូវបានទុកចំហ ហើយពួកគេបារម្ភថាអាចនឹងត្រូវបានបំពេញនៅពេលក្រោយដោយពួកគេមិនដឹង។ នៅទីបំផុតនគរបាលបានយល់ព្រមដកផ្នែកនេះចេញ និងបានដោះលែងអ្នកសារព័ត៌មានបន្ទាប់ពីធ្វើការឃាត់ខ្លួនអស់រយៈពេលជាងពីរម៉ោង។ របាយការណ៍នគរបាលជាលាយលក្ខណ៍អក្សរនៅតែជាកង្វល់ ក្នុងករណីដែលអាចត្រូវប្រើប្រឆាំងនឹងពួកគេនាពេលអនាគត។

## *ថ្ងៃទី១ ខែសីហា ឆ្នាំ២០២៥*

ក្រសួងព័ត៌មានបានចេញនូវសេចក្តីណែនាំដល់ប្រព័ន្ធផ្សព្វផ្សាយសម្រាប់ «អ្នកសារព័ត៌មាន អ្នកបង្កើតមាតិកា និងសាធារណជនទូទៅទាក់ទងនឹងការផ្សាយ ការបោះពុម្ពផ្សាយ និងការចែករំលែកព័ត៌មានទាក់ទងនឹងបញ្ហាព្រំដែន និងមូលដ្ឋានយោធា»។

សេចក្តីណែនាំនេះមានគោលបំណងដើម្បី "ការពារសន្តិសុខជាតិ ធានាសុវត្ថិភាពបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយ លើកកម្ពស់សំឡេងឯកភាពរវាងរដ្ឋាភិបាលនិងសាធារណជន និងធានាការផ្សព្វផ្សាយព័ត៌មានសុក្រឹត្យ និងព័ត៌មានច្បាស់លាស់"។ យោងតាមសេចក្តីណែនាំ បុគ្គលទាំងឡាយណាដែលពាក់ព័ន្ធក្នុងការបង្កើតការផ្សព្វផ្សាយឬមាតិកាត្រូវតែជូនដំណឹងនិងទទួលបានការអនុញ្ញាតពីក្រសួងព័ត៌មាន និងអាជ្ញាធរពាក់ព័ន្ធមុនពេលចូលទៅដល់មូលដ្ឋានយោធាដើម្បីរាយការណ៍ ឬថតរូប។ ការបំពានសេចក្តីណែនាំរបស់ក្រសួងព័ត៌មាននឹងប្រឈមនឹងចំណាត់ការផ្លូវច្បាប់ ហើយ"ខណៈពេលក្រសួងលើកទឹកចិត្តអ្នកសារព័ត៌មាន និងអ្នកបង្កើតមាតិកាឱ្យរាយការណ៍អំពីការពិតសម្រាប់ជាតិ និងអន្តរជាតិដែលក្រសួងណែនាំយ៉ាងមុតមាំឱ្យពួកគេ ពិនិត្យមើលព័ត៌មានដែលមានប្រភពផ្លូវការ។" ប្រភពផ្លូវការទាំងនោះរួមមាន រដ្ឋាភិបាល ក្រសួងការពារជាតិ ក្រសួងការបរទេស ក្រសួងព័ត៌មាន និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

## *ថ្ងៃទី២១ ដល់ ២៧ ខែសីហា ឆ្នាំ២០២៥*

ក្រសួងព័ត៌មានបានដកអាជ្ញាប័ណ្ណផ្សព្វផ្សាយព័ត៌មានអនឡាញ Sara NCC Daily ពាក់ព័ន្ធនឹងការរាយការណ៍របស់ខ្លួនអំពីភាពតានតឹងនៅតាមព្រំដែន ដោយចោទប្រកាន់ថាជាព័ត៌មានមិនពិត និងគំរាមកំហែងដល់សន្តិសុខជាតិ។ មួយថ្ងៃមុននោះ លោក មាស សារ៉ា អ្នករាយការណ៍ព័ត៌មានរបស់សារព័ត៌មាននេះ បានសម្ភាសន៍ជាមួយពលរដ្ឋម្នាក់ដែលរៀបរាប់ពីផ្ទះដែលយោធាថៃ និងប៉ុស្តិ៍យោធាល្បាតនៅតាមព្រំដែនបានរឹបអូស។ អ្នកនាំពាក្យក្រសួងព័ត៌មានបានអះអាងថាករណីនេះគឺជាការបំពានក្រមសីលធម៌យ៉ាងធ្ងន់ធ្ងរ។ ក្នុងការផ្សាយផ្ទាល់តាមបណ្តាញសង្គមហ្វេសប៊ុកក្រោយការដកអាជ្ញាប័ណ្ណ លោក មាស សារ៉ា បញ្ជាក់ថា លោកនឹងលែងធ្វើការជាអ្នកសារព័ត៌មានទៀតហើយ ប៉ុន្តែបន្តយកព័ត៌មានក្នុងនាមជាពលរដ្ឋ។

ប៉ុន្មានថ្ងៃក្រោយមក គឺនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៥ លោក មាស សារ៉ា ត្រូវបានចាប់ខ្លួននៅខេត្តបន្ទាយមានជ័យ។ គាត់បានធ្វើការផ្សាយផ្ទាល់អំពីការតវ៉ារបស់ពលរដ្ឋថៃមួយក្រុមនៅភូមិណងចាន់ នៅក្នុងប្រទេសថៃ ប្រឆាំងនឹងពលរដ្ឋខ្មែរដែលកំពុងឃ្លាំមើលយោធាថៃដំឡើងរបងលួសបន្លា។ ក្នុងពេលតវ៉ានោះ

អាជ្ញាធរខេត្តបានរារាំងអ្នកសារព័ត៌មាននៅភូមិជោគជ័យ ខាងទឹកដីកម្ពុជាមិនឱ្យផ្សាយផ្ទាល់អំពីការតវ៉ានោះទេ។ នៅថ្ងៃបន្ទាប់ គាត់បានទៅបង្ហាញខ្លួននៅចំពោះមុខសាលាដំបូងខេត្តបន្ទាយមានជ័យ និងរងការចោទប្រកាន់ពីបទ "ញុះញង់" ដែលអាចផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់២ឆ្នាំ។ គាត់ត្រូវបានដោះលែងឱ្យនៅក្រៅឃុំនៅថ្ងៃនោះ ហើយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ ការដោះលែងគាត់បានធ្វើឡើងបន្ទាប់ពីភរិយារបស់គាត់បានបង្ហោះសារសុំទោសជាសាធារណៈតាមអ៊ីនធឺណិត។

## *ថ្ងៃទី៣១ ខែកក្កដា ដល់ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៥*

អ្នកសារព័ត៌មានពីរនាក់ដែលធ្វើការឱ្យប្រព័ន្ធផ្សព្វផ្សាយ TSP 68 TV Online គឺលោក ផន សុភាព និងលោក ភាព ភារ៉ា ត្រូវបានចាប់ខ្លួនដាច់ដោយឡែកពីគ្នា បន្ទាប់ពីត្រឡប់មកពីព្រំដែន។ អ្នកទាំងពីរត្រូវបានចោទប្រកាន់តាមមាត្រា៤៤៥ នៃក្រមព្រហ្មទណ្ឌ «បទប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ» ជាបទចោទដែលអាចជាប់ពន្ធនាគារពី ៧ ដល់ ១៥ ឆ្នាំ។ ការចោទប្រកាន់នេះហាក់ដូចជាពាក់ព័ន្ធនឹងការបង្ហោះសារនៅលើហ្វេសប៊ុក ទាក់ទងនឹងជម្លោះ បើទោះបីជានៅមិនទាន់ច្បាស់ថាការបង្ហោះ ឬព័ត៌មានណាមួយពិតប្រាកដក៏ដោយ។ អ្នកទាំងពីរត្រូវបានឃើញនៅក្នុងរូបថតជាមួយទាហានខ្មែរជាច្រើននាក់នៅមុខប្រាសាទតាក្របី ដែលត្រូវបានប្រព័ន្ធផ្សព្វផ្សាយថៃប្រើប្រាស់យ៉ាងទូលំទូលាយ ដោយចោទប្រកាន់ថាគ្រាប់មីនមិនទាន់ដាក់បង្កប់អាចមើលឃើញនៅផ្ទៃខាងក្រោយ ហើយរូបថតនេះត្រូវបានថតបន្ទាប់ពីបទឈប់បាញ់កាលពីថ្ងៃទី២៨ ខែកក្កដា។ អ្នកសារព័ត៌មានទាំងពីរនាក់កំពុងជាប់ឃុំបណ្តោះអាសន្ននៅខេត្តសៀមរាប។

នៅថ្ងៃទី១ ខែកញ្ញា ភរិយាលោក ភាព ភារ៉ា បានចេញវីដេអូមួយនៅលើទំព័រហ្វេសប៊ុក ធ្វើការសុំទោសប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី និងអំពាវនាវឱ្យលោកទាំងពីរជួយអន្តរាគមន៍ក្នុងរឿងនេះ។

នៅថ្ងៃទី១០ ខែកញ្ញា សាលាដំបូងខេត្តសៀមរាបបានបញ្ជាក់ថា អ្នកសារព័ត៌មានទាំងពីរនាក់ត្រូវបានចោទប្រកាន់ពីបទ"ប្រគល់ឱ្យរដ្ឋបរទេសនូវព័ត៌មានជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការការពារជាតិ" ហើយសំណុំរឿងនេះត្រូវបានបញ្ជូនទៅកាន់ចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបអង្កេតបន្ត។

## បទពិសោធន៍របស់អ្នកសារព័ត៌មាន

តាមរយៈបទសម្ភាសរបស់ម.ស.ម.ក ជាមួយអ្នកសារព័ត៌មានដែលបានយកព័ត៌មានអំពីជម្លោះព្រំដែនបានលើកឡើងប្រធានបទមួយចំនួនៈ កង្វះការការពារទាំងផ្នែករដ្ឋបាលនិងផ្នែករូបវន្តធ្វើឱ្យមានអារម្មណ៍អសន្តិសុខ កង្វះខាតការផ្តល់ព័ត៌មានគួរទុកចិត្តនិងទាន់ពេលវេលាពីសំណាក់រដ្ឋាភិបាល ស្តង់ដារផ្សេងគ្នាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយផ្សេងគ្នា ការភ័យខ្លាចពីការចោទប្រកាន់ព្រហ្មទណ្ឌពីសកម្មភាពការរាយការណ៍របស់ពួកគេ និងកត្តាផ្សេងៗបានបង្កើតលក្ខខណ្ឌសម្រាប់ព័ត៌មានមិនពិតដើម្បីផ្សព្វផ្សាយតាមអនឡាញ។ ប្រធានបទនីមួយៗនេះត្រូវបានពន្យល់លម្អិតដូចតទៅៈ

## *កង្វះការការពារផ្នែករដ្ឋបាល និងផ្នែករូបវ័ន្ត ដែលធ្វើឱ្យមានអារម្មណ៍ថាអសន្តិសុខ*

អ្នកសារព័ត៌មានជាច្រើនដែលបានផ្ដល់បទសម្ភាសជាមួយ ម.ស.ម.ក បានកត់សម្គាល់ថា ការមិនមានការការពារផ្នែករដ្ឋបាលដូចជាប័ណ្ណសម្គាល់អ្នកសារព័ត៌មាន ឬឧបករណ៍ការពាររាងកាយដូចជាអាវក្រោះ ឬមួកសុវត្ថិភាព បានធ្វើឱ្យមានអារម្មណ៍អសន្តិសុខចំពោះការរាយការណ៍ព័ត៌មានពីតំបន់ជម្លោះ។

បញ្ហានៃប័ណ្ណសំគាល់អ្នកសារពត៌មានគឺជាកង្វល់មួយសម្រាប់អ្នកសារព័ត៌មានដែលគ្មានអង្គភាព ដោយពួកគេមួយចំនួនបាននិយាយថាពួកគេបានដាក់ពាក្យសុំតាមរយៈក្រសួងព័ត៌មានជាច្រើនដងមុនពេលមានជម្លោះ ប៉ុន្តែមិនបានទទួលការឆ្លើយតបណាមួយ ឬក្រសួងបានស្នើសុំព័ត៌មានលម្អិតអំពីការងារ និងនិយោជកពីមុនរបស់គេ។ គួររំឭកថា ប្រព័ន្ធរបស់រដ្ឋក្នុងការចុះឈ្មោះអ្នកសារព័ត៌មានគឺមិនស្របនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិនោះទេ ហើយដែលអាចអនុញ្ញាតបានតែ «ក្នុងករណីចាំបាច់ដើម្បីផ្តល់ឱ្យអ្នកសារព័ត៌មាននូវសិទ្ធិចូលទៅកាន់ទីកន្លែង និង/ឬព្រឹត្តិការណ៍មួយចំនួន» ហើយអនុវត្តដោយគ្មានការរើសអើង។ [1]

អ្នកសារព័ត៌មានដែលគ្មានអង្គភាពជាច្រើននាក់ ធ្លាប់បានបម្រើការងារឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែលរដ្ឋាភិបាលបានបិទ ឬប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដែលបុគ្គលមាននិន្នាការទៅរករដ្ឋាភិបាលបានទិញយក។[2] អ្នកសារព័ត៌មានម្នាក់បានកត់សម្គាល់ថាការរាយការណ៍ព័ត៌មាននៅតំបន់ជម្លោះក្នុងនាមជាអ្នកសារព័ត៌មានដែលគ្មានអង្គភាព កាន់តែធ្វើឱ្យមានអារម្មណ៍តានតឹងថា «ខ្ញុំបានគិតខ្លួនឯងថា ចុះបើមានអ្វីកើតឡើងចំពោះខ្ញុំ? ខ្ញុំមិនមានស្ថាប័នសម្រាប់ជួយខ្ញុំក្នុងករណីមានរឿងអ្វីមួយកើតឡើងនោះទេ»។

អ្នកសារព័ត៌មានខ្លះបានបង្ហាញប័ណ្ណសម្គាល់អ្នកសារព័ត៌មានដែលហួសសុពលភាពរបស់ខ្លួននៅពេលសុំចូល ហើយដែលជាទូទៅត្រូវបានគេទទួលយក ខណៈអ្នកខ្លះទៀតដែលគ្មានប័ណ្ណសម្គាល់ តែបានបង្ហាញលិខិតបេសកកម្ម ហើយជាទូទៅក៏ត្រូវបានទទួលយកផងដែរ។ សរុបមក ការមិនមានប័ណ្ណសំគាល់អ្នកសារព័ត៌មាន ឬប័ណ្ណផុតសុពលភាព គឺជាកង្វល់ដ៏ធំមួយសម្រាប់អ្នកសារព័ត៌មានមួយចំនួន ដែលមានការព្រួយបារម្ភបន្ថែមលើការរាយការណ៍នៅតំបន់ជម្លោះ។ អ្នកសារព័ត៌មានបានបារម្ភថាខ្លួននឹងមិនត្រូវបានអនុញ្ញាតឱ្យចូលយកព័ត៌មាន ឬអាចនឹងត្រូវបានពិន័យចំពោះការមិនមានប័ណ្ណសម្គាល់អ្នកសារព័ត៌មាន។ គួរកត់សម្គាល់ថា អ្នក

---

[1] គណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ, សេចក្តីពន្យល់ទូទៅ លេខ៣៤,កតិកាសញ្ញាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ /C/GC/34, ៖៤៤

[2] សំឡេងសហរដ្ឋអាមេរិក (វីអូអេ), លក់កាសែតភ្នំពេញផុសឱ្យទៅអ្នកវិនិយោគជនជាតិមាឡេស៊ី។
ប៊ីប៊ីស៊ី (BBC), កាសែតភ្នំពេញប៉ុស្ត,ការដកចេញ និងការដាក់ពាក្យឈប់ បន្ទាប់ពីលក់កាសែតខេមរាឌៃលី។
រយទ័រ (Reuters), ការសែឯករាជ្យចុងក្រោយរបស់ប្រទេសកម្ពុជាលក់ឱ្យជនជាតិមាឡេស៊ី។
អាហ្សាសេរ៉ា (Al Jazeera), កាសែតភ្នំពេញប៉ុស្ដិ៍លក់ឱ្យលោកស៊ីវ៉ាគុម៉ាជីដែលជាជនជាតិមាឡេស៊ី។
អ្នកសារព័ត៌មានគ្មានព្រំដែន, លោក ហ៊ុន សែន មានទំនាក់ទំនងជាមួយក្រុមហ៊ុន PR ក្នុងការទិញកាសែតឯករាជ្យចុងក្រោយរបស់ប្រទេសកម្ពុជា។

សារព័ត៌មានដែលគ្មានអង្គភាពវ័យក្មេងជាច្រើននាក់បានរាយការណ៍ថា មិនបានធ្វើដំណើរទៅយកព័ត៌មាននៅតំបន់ជម្លោះនោះទេ ដោយសារពួកគេបារម្ភពីហានិភ័យនៃការរាយការណ៍ដោយមិនមានប័ណ្ណសម្គាល់អ្នកព័ត៌មាន ហើយគិតថាពួកគេនឹងមិនត្រូវបានផ្តល់សិទ្ធិចូលយកព័ត៌មាន។

កង្វះឧបករណ៍ការពារសម្រាប់អ្នកសារព័ត៌មានក៏ជាកង្វល់ និងជាហានិភ័យធ្ងន់ធ្ងរផងដែរ។ អ្នកសារព័ត៌មានជាច្រើនដែលរាយការណ៍ពីតំបន់ជម្លោះនេះ មិនទាន់មានមួកសុវត្ថិភាព ឬអាវក្រោះ ឬមិនបានទទួលភ្លាមៗនោះទេនូវឧបករណ៍ការពារ ដូច្នេះពួកគេបានចែករំលែកឱ្យគ្នាទៅវិញទៅមក។ អ្នកសារព័ត៌មានម្នាក់បានរំលឹកថាក្នុងក្រុមអ្នកសារព័ត៌មានទាំង ០៧នាក់ មានតែអាវក្រោះការពារគ្រាប់កាំភ្លើងតែមួយប៉ុណ្ណោះ។ ម្នាក់ទៀតបានរៀបរាប់ពីការបើកបរឆ្លងខេត្តដើម្បីខ្ចីឧបករណ៍សម្រាប់ការពារពីអ្នកសារព័ត៌មានផ្សេងទៀត មានន័យថាពួកគេត្រូវបានចេញទៅយកព័ត៌មានដោយមិនមានអាវក្រោះ តែទោះយ៉ាងណា ពួកគេក៏នៅតែបន្តរាយការណ៍អំពីជម្លោះ។

អ្នកសារព័ត៌មានមួយចំនួនបានបង្ហាញ និង/ឬមានអារម្មណ៍ថាមានហានិភ័យកើតឡើងបីចំណុច ដោយសារមិនមានឧបករណ៍ការពារ ប័ណ្ណសម្គាល់អ្នកសារព័ត៌មាន ឬការគាំទ្រពីអង្គភាពសារព័ត៌មានរបស់ពួកគេ។ ការការពារអប្បរមានៃប័ណ្ណសម្គាល់អ្នកសារព័ត៌មាន និងឧបករណ៍ការពារនឹងផ្តល់ឱ្យអ្នកសារព័ត៌មាននូវកម្រិតសុវត្ថិភាពមូលដ្ឋាន ខណៈពេលធ្វើការរាយការណ៍ពីតំបន់ជម្លោះ។

## *កង្វះខាតការផ្តល់ព័ត៌មានគួរទុកចិត្ត និងទាន់ពេលវេលាពីសំណាក់រដ្ឋាភិបាល*

អ្នកសារព័ត៌មានដែល ម.ស.ម.ក បានសម្ភាស លើកឡើងពីការលំបាកក្នុងការទទួលព័ត៌មានគ្រប់គ្រាន់ និងទាន់ពេលវេលាពីប្រភពផ្លូវការ ដូចជាក្រសួង និងកង្វះការសម្របសម្រួលក្នុងការផ្តល់ព័ត៌មានជាដើម។ សំណួរ និងសំណើរបស់ពួកគេសម្រាប់ព័ត៌មានថ្មីៗអំពីជម្លោះ ដូចជាចំនួនអ្នកស្លាប់ ឬចំនួនមនុស្សផ្លាស់ទីលំនៅ មិនទទួលបានការឆ្លើយតប ឬមានការពន្យារពេលក្នុងការឆ្លើយតប។ នៅពេលដែលពួកគេបានទទួលព័ត៌មាន ឬការឆ្លើយតប ជារឿយៗមិនទាន់ពេលវេលា ឬមិនមានពេលគ្រប់គ្រាន់ ដែលរារាំងលទ្ធភាពរបស់ពួកគេក្នុងការរាយការណ៍អំពីជម្លោះ។ ជាងនេះទៅទៀត សំណើជាច្រើនក្នុងការសម្ភាសអ្នកនាំពាក្យក្រសួងការពារជាតិ និងក្រសួងព័ត៌មាន ក៏មិនមានការឆ្លើយតបផងដែរ។ ចំណុចនេះមានសារៈសំខាន់ ដោយសារសេចក្តីណែនាំស្តីពីប្រព័ន្ធផ្សព្វផ្សាយដែលក្រសួងព័ត៌មានបានចេញកាលពីដើមខែសីហា «ផ្តល់ដំបូន្មានយ៉ាងមុតមាំ» អ្នកសារព័ត៌មានឱ្យ "ពិនិត្យមើលព័ត៌មានទាំងអស់ជាមួយប្រភពផ្លូវការ" ទោះបីជាអ្នកសារព័ត៌មានដែល ម.ស.ម.ក បានសម្ភាស បានលើកឡើងពីការលំបាកក្នុងការធ្វើដូច្នេះក៏ដោយ។

អ្នកសារព័ត៌មានមួយចំនួនដែលបាននិយាយទៅកាន់ ម.ស.ម.ក បានចែករំលែកថា ពួកគេយល់ឃើញថាសន្និសីទសារព័ត៌មានដែលធ្វើឡើង ឬសេចក្តីថ្លែងការណ៍ដែលចេញផ្សាយដោយក្រសួងមិនបានផ្តល់ព័ត៌មានលម្អិត និងជាក់លាក់ដែលពួកគេអាចប្រើប្រាស់សម្រាប់ការរាយការណ៍នោះទេ។ អ្នកសារព័ត៌មានក៏បានឆ្លុះបញ្ចាំងទៅនឹងកាលបោះឆ្នោតកន្លងទៅថា បញ្ជីលេខទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធត្រូវបានចែកនិងផ្តល់

ជូនដល់ទៅប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងគោលបំណងស្វែងរកព័ត៌មាន និងការបំភ្លឺ ប៉ុន្តែនៅក្នុងជម្លោះព្រំដែន មិនបានធ្វើដូច្នេះនោះទេ។

ភាគីខាងអាជ្ញាធរនិងយោធាហាក់ខ្វះភាពច្បាស់លាស់ ថាតើព័ត៌មានណាខ្លះអាចប្រាប់អ្នកសារព័ត៌មានបាននិងពីនរណា ដែលអ្នកសារព័ត៌មានជាច្រើនតែងតែឮថាគេត្រូវសួរថ្នាក់លើ ហើយករណីនេះកើតឡើងជាច្រើនដងចំពោះសំណួរដដែលៗ ឬព័ត៌មានដែលត្រូវបានស្នើសុំ។

អ្នកសារព័ត៌មានមួយចំនួនដែលបានរាយការណ៍ពីជម្លោះរវាងកម្ពុជានិងថៃក្នុងឆ្នាំ២០០៨ និងឆ្នាំ ២០១១ បានកត់សម្គាល់ពីភាពខុសគ្នាក្នុងការទទួលព័ត៌មាន។ តាមបទពិសោធន៍របស់ពួកគេ គឺការលំបាកក្នុងការទទួលបានព័ត៌មានពីអាជ្ញាធរក្នុងជម្លោះបច្ចុប្បន្ន ដោយសារមន្ត្រីទទួលបន្ទុកមិនសូវមានឆន្ទៈក្នុងការនិយាយជាមួយពួកគេ និងឱ្យសាកសួរទៅថ្នាក់លើរបស់ពួកគេ។ មិនមានភាពច្បាស់ទេថាតើការមិនមានឆន្ទៈឆ្លើយតបនេះគឺស្របតាមការណែនាំដែលពួកគេបានទទួល ភាពមិនច្បាស់លាស់ទាក់ទងនឹងសមត្ថភាពរបស់ពួកគេក្នុងការចែករំលែកព័ត៌មាន ឬការភ័យខ្លាចចំពោះផលប៉ះពាល់ដែលអាចកើតមាន។

អ្នកសារព័ត៌មានខ្លះបានថ្លែងថា ជាទូទៅពួកគេត្រូវបានអនុញ្ញាតឱ្យចូលទៅកាន់តំបន់នានា ហើយយល់ថាអាជ្ញាធរមិនសូវរឹតត្បិតពួកគេដូចដែលពួកគេធ្លាប់ជួបកន្លងមកនៅពេលរាយការណ៍ព័ត៌មាន ដោយមើលទៅហាក់ដូចជាអាជ្ញាធរសប្បាយចិត្តដែលជម្លោះនេះត្រូវបានរាយការណ៍។ ម៉្យាងវិញទៀត អ្នកសារព័ត៌មានខ្លះទៀតប្រឈមមុខនឹងការលំបាកក្នុងការចូលទៅកាន់តំបន់ជម្លោះ ហើយត្រូវបានរារាំងក្នុងការចូលទៅកាន់ទីតាំង ឬរារាំងក្នុងការថតរូបទីតាំងមួយចំនួន។ អ្នកសារព័ត៌មានស្ត្រីម្នាក់បានរំឭកថា អាជ្ញាធរបានបដិសេធក្នុងការចូលទៅកាន់តំបន់មួយ ដែលអ្នកសារព័ត៌មានផ្សេងទៀតត្រូវបានអនុញ្ញាតឱ្យចូល ដោយលើកឡើងអំពីភេទរបស់គាត់ជាហេតុផលមិនឱ្យចូល។

## *ការភ័យខ្លាចនៃការចោទប្រកាន់ពីបទព្រហ្មទណ្ឌចំពោះការរាយការណ៍*

ក្ដីបារម្ភចម្បងសម្រាប់ការអនុវត្តជាក់ស្ដែងរបស់អ្នកសារព័ត៌មានទាំងអស់ដែល ម.ស.ម.ក បានសម្ភាស គឺការដែលត្រូវចោទប្រកាន់ពីបទព្រហ្មទណ្ឌសម្រាប់ការរាយការណ៍របស់ពួកគេ ជាពិសេសចោទថា ជាអ្នកស៊ើបការណ៍ និងវិធានការផ្លូវច្បាប់ត្រូវធ្វើឡើងប្រឆាំងនឹងពួកគេ។ ការគំរាមកំហែងនៃចំណាត់ការផ្លូវច្បាប់ គឺជាការព្រួយបារម្ភឥតឈប់ឈរសម្រាប់អ្នកសារព័ត៌មានឯករាជ្យ និងបណ្ដាញផ្សព្វផ្សាយនានានៅក្នុងប្រទេសកម្ពុជា ទោះបីជាមិនមានជម្លោះក៏ដោយ ប៉ុន្តែការព្រួយបារម្ភនេះត្រូវបានកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងបរិបទនៃជម្លោះ។

យ៉ាងហោចណាស់អ្នកសារព័ត៌មានពីរនាក់បានរាយការណ៍ថាត្រូវបានគំរាមកំហែងចាប់ខ្លួន ខណៈពេលដែលរាយការណ៍អំពីជម្លោះ រីឯអ្នកខ្លះទៀតបានចែករំលែកថា ឮព័ត៌មានអំពីអ្នកសារព័ត៌មានផ្សេងទៀតត្រូវបានឃុំខ្លួន គឺបានធ្វើឱ្យពួកគេ និងអ្នកខ្លះទៀតមិនហ៊ានរាយការណ៍ពីជម្លោះនេះដោយសារតែពួកគេខ្លាចអាចនឹងត្រូវឃុំខ្លួនផងដែរ។ អ្នកសារព័ត៌មានម្នាក់បានឆ្លុះបញ្ចាំងថា «ខ្ញុំយល់ថាខ្ញុំខ្លាចការឃុំខ្លួនពីអាជ្ញា

ធរដោយសារការរាយការណ៍អំពីជម្លោះ ដាងការវាយប្រហារដោយគ្រាប់ផ្លោង ឬត្រូវបានវាយប្រហារដោយកាំជ្រួចក្នុងអំឡុងពេលជម្លោះនោះទៅទៀត»។

អ្នកសារព័ត៌មានមួយចំនួនបានរំលឹកថា ពួកគេបានព្យាយាមវាយតម្លៃជានិច្ចនូវអ្វីដែលពួកគេអាច និងមិនអាចរាយការណ៍បាន ហើយថាតើនឹងត្រូវបានចាត់ទុកថាមានគ្រោះថ្នាក់ដល់សន្តិសុខជាតិដែរឬទេ។ អ្នកសារព័ត៌មានម្នាក់បានប្រាប់ ម.ស.ម.ក ថា៖ «ខ្ញុំបានសួរខ្លួនឯងឥតឈប់ឈរ តើព័ត៌មាននេះអាចរាយការណ៍បានទេ? វាពិតជាពិបាកក្នុងការដឹងណាស់»។ ខណៈដែលសំណួរពីបញ្ហាជម្លោះព្រំដែនមិនអាចចៀសផុតក្នុងការរាយការណ៍ អ្នកសារព័ត៌មានកង្វល់ជុំវិញសំណួរដែលមិនអាចត្រូវបានបំបែកចេញពីបរិបទប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាដែលពួកគេកំពុងបំពេញការងារអ្នកសារព័ត៌មាននិងតួអង្គសង្គមស៊ីវិលផ្សេងទៀតជារឿយៗត្រូវចោទប្រកាន់ពីបទ "ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម" (មាត្រា ៤៩៤ និង ៤៩៥ នៃក្រមព្រហ្មទណ្ឌ) ចំពោះការរាយការណ៍របស់លើបញ្ហាដែលជាផលប្រយោជន៍សាធារណៈ។ លើសពីនេះ ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានឆ្នាំ២០២៤ ចែងថា អ្នកសារព័ត៌មាននិងស្ថាប័នសារព័ត៌មាននានាគួរតែ "ជៀសវាងការបោះពុម្ពផ្សាយខ្លឹមសារដែលប៉ះពាល់ដល់សន្តិភាព សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ សុខដុមរមនា សាសនាប្រពៃណី និងទំនៀមទម្លាប់ល្អរបស់ប្រទេសជាតិ និងសង្គមនិងសិទ្ធិរបស់អ្នកដទៃ" (ចំណុច ១១) និង "មិនត្រូវផ្សព្វផ្សាយព័ត៌មានដែលបង្កមហន្តរាយដល់សណ្តាប់ធ្នាប់សាធារណៈ ប៉ះពាល់ដល់ស្ថិរភាពសន្តិសុខសង្គម និងសន្តិសុខជាតិ" (ចំណុច ២៦.៥)។ ដូច្នេះ មិនមែនជារឿងគួរឱ្យភ្ញាក់ផ្អើលដែលអ្នកសារព័ត៌មានមួយចំនួនភ័យខ្លាចថាការរាយការណ៍របស់ពួកគេនឹងមានលក្ខណៈខុសដោយចេតនាជាការគំរាមកំហែងដល់សន្តិសុខជាតិ។

ភាពមិនច្បាស់លាស់អំពីអ្វីដែលអាចនិងមិនអាចផ្សព្វផ្សាយបាន និងផលវិបាកដែលអាចកើតមាន បាននាំឱ្យអ្នកសារព័ត៌មានជាច្រើនបដិសេធក្នុងការផ្សព្វផ្សាយអត្ថបទដែលពួកគេបានសរសេរឬប្រើប្រាស់វីដេអូដែលពួកគេបានថត និងកិច្ចសម្ភាសន៍ដែលពួកគេបានធ្វើ។ ការដាក់កំហិតខ្លួនឯងបែបនេះបណ្តាលមកពីការរឹតត្បិតលើប្រព័ន្ធផ្សព្វផ្សាយពីសំណាក់រដ្ឋាភិបាលកម្ពុជា គឺជាសូចនាករនៃការធ្លាក់ចុះនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។ ទោះបីជាអ្នកសារព័ត៌មានបានអនុវត្តការយកព័ត៌មានដោយយកចិត្តទុកដាក់ និងធានានូវភាពត្រឹមត្រូវនៃព័ត៌មាននិងប្រភពច្បាស់លាស់ ក៏អ្នកសារព័ត៌មានមួយចំនួននៅតែគិតថា ការរាយការណ៍ព័ត៌មានរបស់ខ្លួននឹងត្រូវគេចាត់ទុកថាជាព័ត៌មានមិនពិត ឬមិនពេញលេញ។ អារម្មណ៍តានតឹងចំពោះបញ្ហានេះ ហើយអារម្មណ៍មិនប្រាកដប្រជានិងការភ័យខ្លាចបែបនេះទើបនាំឱ្យបង្អាក់លទ្ធភាពរបស់អ្នកសារព័ត៌មានក្នុងការរាយការណ៍អំពីជម្លោះ ដែលនេះបានជះឥទ្ធិពលដល់ការរាយការណ៍ព័ត៌មានទាំងមូលនៃជម្លោះ។

អ្នកសារព័ត៌មានខ្លះក៏បានរៀបរាប់ថាពួកគេបានយល់ឃើញថា ពលរដ្ឋដែលរងផលប៉ះពាល់ពីជម្លោះមានការស្ទាក់ស្ទើរក្នុងការនិយាយជាមួយ ឬផ្តល់ព័ត៌មានដល់ពួកគេ ហាក់ដូចជាដោយសារតែការភ័យខ្លាច។ បន្ទាប់មក អ្នកសារព័ត៌មានក៏មិនផ្សព្វផ្សាយនូវព័ត៌មានទាំងនោះ ដើម្បីកាត់បន្ថយហានិភ័យណាមួយដល់បុគ្គលដែលបានផ្តល់ព័ត៌មាននោះ។

ការចោទប្រកាន់ថាជាចារកម្មគឺជារឿងមួយដែលអ្នកសារព័ត៌មានបានដឹងច្បាស់។ អ្នកសារព័ត៌មានម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានដែលបានផ្តល់កិច្ចសម្ភាសជាមួយ ម.ស.ម.ក ត្រូវបានអាជ្ញាធរបដិសេធក្នុងការចូលទៅតំបន់ជម្លោះ ដែលបានលើកឡើងថា ពួកគេអាចជាចារកម្ម ហើយបានបន្តសួរនាំពួកគេនូវសំណួរមួយចំនួន។ ដូចបានរៀបរាប់ខាងលើ នៅពេលដែលនគរបាលកំពុងសាកសួរអ្នកសារព័ត៌មានពីរនាក់ដែលត្រូវបានឃាត់ខ្លួន ការចោទប្រកាន់ថាជាចារកម្មក៏ត្រូវបានលើកឡើងស្រដៀងគ្នាដែរ។ សូម្បីតែអ្នកសារព័ត៌មានដែលមិនបានប្រឈមមុខបែបនេះ ខណៈពេលដែលរាយការណ៍អំពីជម្លោះនោះ បានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំង។ ក្នុងឆ្នាំ២០១៧ អតីតអ្នកសារព័ត៌មានវិទ្យុអាស៊ីសេរីពីរនាក់ ត្រូវបានចោទប្រកាន់ពីបទ ផ្តល់ឱ្យរដ្ឋបរទេសនូវព័ត៌ជាអាទិ៍ដែលអាចធ្វើឱ្យអន្តរាយការពារជាតិ តាមមាត្រា ៤៤៥ នៃក្រមព្រហ្មទណ្ឌ ក្នុងសំណុំរឿងផ្លូវច្បាប់ដែលអូសបន្លាយ និងកំពុងដំណើរការ។ ពេលថ្មីៗនេះ ការចោទប្រកាន់ត្រូវបានធ្វើឡើងជាថ្មីម្តងទៀតប្រឆាំងនឹងអ្នកសារព័ត៌មានពីររូបដែលចុះផ្សាយរឿងជម្លោះព្រំដែន គឺលោក ផន សុភាព និងលោក ភាព ភារ៉ា ដូចបានលើកឡើងខាងលើ។ ការចោទប្រកាន់បែបនេះកំពុងតែជាក្តីបារម្ភនៅក្នុងបរិបទនៃការធ្វើវិសោធនកម្មច្បាប់ស្តីពីសញ្ជាតិក្នុងខែកញ្ញា ឆ្នាំ២០២៥។ ជាលទ្ធផលនៃវិសោធនកម្មមាត្រា ២៩ នៃច្បាប់ស្តីពីសញ្ជាតិចែងថា សញ្ជាតិអាចត្រូវបានដកហូតវិញ ប្រសិនបើបុគ្គលបានប្រព្រឹត្ត "អំពើក្បត់ជាតិឬឃុបឃិតជាមួយបរទេស ដែលនាំឱ្យអន្តរាយដល់ផលប្រយោជន៍ស្នូលនៃព្រះរាជាណាចក្រកម្ពុជា។" "ធ្វើសកម្មភាពដែលអន្តរាយដល់អធិបតេយ្យភាពជាតិ បូរណភាពទឹកដី និងសន្តិសុខជាតិ" ឬ "ប្រសិនបើពួកគេត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមពាក់ព័ន្ធនឹងការបំពានលើព្រះមហាក្សត្រ ប៉ះពាល់ដល់សន្តិសុខរដ្ឋ ឬអំពើភេរវកម្ម"។ ដោយគិតពីចរិតនៃការចោទប្រកាន់ពីបទចារកម្ម និងនៅក្នុងបរិបទនៃជម្លោះនេះ មិនអាចប្រកែកបានថាបុគ្គលដែលត្រូវបានចោទប្រកាន់តាមមាត្រា ៤៤៥ អាចងាយនឹងទទួលរងនូវការដកហូតសញ្ជាតិក្រោមច្បាប់ស្តីពីសញ្ជាតិផងដែរ។

អ្នកសារព័ត៌មានជាច្រើននាក់ក៏បានរំឮកថា អាជ្ញាធរបានថតរូប និងរថយន្តរបស់ពួកគេ បានធ្វើឱ្យមានការភ័យខ្លាចភ្លាមៗចំពោះការដែលរូបថតនេះអាចត្រូវប្រើប្រាស់ ឬចេតនាណាមួយរបស់អាជ្ញាធរ។

គួររំលឹកថា នៅក្រោមច្បាប់មនុស្សធម៌អន្តរជាតិ អ្នកសារព័ត៌មានដែលបំពេញការងារវិជ្ជាជីវៈក្នុងជម្លោះប្រដាប់អាវុធត្រូវបានការពារក្នុងនាមជាជនស៊ីវិល ហើយត្រូវបានចាត់ទុកជាជនស៊ីវិល។[3] អនុលោមតាមការការពារនេះ អ្នកសារព័ត៌មានមិនត្រូវបានកំណត់ជាគោលដៅឡើយ ហើយ "ត្រូវតែគោរព និងការពារ ដរាបណាពួកគេមិនបានចូលរួមដោយផ្ទាល់នៅក្នុងជម្លោះ" និងមិនទទួលរងនូវការចាប់ខ្លួន ការឃុំខ្លួន ការឃាយឃី ឬការបំភិតបំភ័យ។[4]

---

[3] ពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវ,មាត្រា ៧៩។

[4] គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម, ច្បាប់ប្រពៃណីអន្តរជាតិៈ ភាគ១, បទបញ្ញត្តិ ៣៤ អ្នកសារព័ត៌មាន(ឆ្នាំ២០០៥)។

## ស្តង់ដារផ្សេងគ្នាសម្រាប់ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗគ្នា

អ្នកសារព័ត៌មានជាច្រើននាក់បានរំលឹកឡើងអំពីការប្រព្រឹត្តផ្សេងៗគ្នាពីសំណាក់អាជ្ញាធររវាងស្ថាប័នសារព័ត៌មាននិងអ្នកសារព័ត៌មានឯករាជ្យ និងអ្នកដែលត្រូវបានចាត់ទុកថាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល។ ទីតាំងដែលប្រព័ន្ធផ្សព្វផ្សាយទាំងនោះកំពុងធ្វើការរាយការណ៍ អ្នកសារព័ត៌មានដែលបំរើការឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងអ្នកសារព័ត៌មានដែលគ្មានអង្គភាពអាចចំណាយពេលច្រើនក្នុងការព្យាយាមដើម្បីទទួលបានការយល់ព្រមពីបុគ្គលមួយចំនួនដើម្បីទទួលបានការអនុញ្ញាតចូលទៅយកព័ត៌មានពីតំបន់នោះដែរ។ ក្នុងហេតុការណ៍ដែលបានលើកឡើងខាងលើនេះ អ្នកសារព័ត៌មានពីរក្រុមត្រូវបានឃាត់ខ្លួននៅក្រុងសំរោងសមត្ថកិច្ចប្រាប់ពួកគេទាំងពីរក្រុមថាមិនអាចប្រើប្រាស់ទូរស័ព្ទបានទេ ដោយសារហានិភ័យនឹងការចាប់ទីតាំងតាមប្រព័ន្ធជីភីអេស (GPS)។ បញ្ហានេះត្រូវបានធ្វើឡើង បើទោះបីជាប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដែលមាននិន្នាការលើរដ្ឋាភិបាលកំពុងផ្សាយពីតំបន់នោះ ដោយហានិភ័យនៃការចាប់ប្រព័ន្ធជីភីអេស ហាក់ដូចជាមិនអនុវត្តចំពោះពួកគេ។

ដោយសារស្ថាប័នផ្សេងទៀតដែល ម.ស.ម.ក ធ្វើការទាក់ទងស្នើសុំសម្ភាសហាក់មិនមានឆន្ទៈក្នុងការផ្តល់បទសម្ភាសន៍។ ដូច្នេះ ម.ស.ម.ក មិនអាចធ្វើការឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ពួកគេក្នុងការរាយការណ៍ពីតំបន់ជម្លោះនៅក្នុងកំណត់ត្រាសង្ខេបនេះទេ។

## កត្តាផ្សេងៗនាំឱ្យមានការផ្សព្វផ្សាយព័ត៌មានមិនពិត

ព័ត៌មានក្លែងក្លាយ និងព័ត៌មានមិនពិតអំពីជម្លោះដែលរីកសាយភាយនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមទាំងគណនីភាសាខ្មែរ និងភាសាថៃ គឺជាក្តីកង្វល់ និងជាប្រភពនៃការខកចិត្តយ៉ាងខ្លាំងសម្រាប់អ្នកសារព័ត៌មានជាច្រើន។

ដើម្បីបង្ហាញឱ្យស៊ីជម្រៅអំពីប្រភេទនៃព័ត៌មានក្លែងក្លាយ និងព័ត៌មានមិនពិតដែលទទួលបានការចាប់អារម្មណ៍ខ្លាំងនៅលើអនឡាញ ឧទាហរណ៍មួយគឺរូបថតយន្តហោះអាមេរិកទម្លាក់សារធាតុពន្លត់អគ្គីភ័យ ដែលត្រូវបានយកមកប្រើប្រាស់ដើម្បីចោទប្រកាន់ថា កងទ័ពថៃបានប្រើប្រាស់អាវុធគីមី ខណៈដែលការពិតរូបថតនោះបង្ហាញពីកិច្ចការពន្លត់អគ្គិភ័យក្នុងអំឡុងពេលភ្លើងឆេះព្រៃនៅទីក្រុង Los Angeles កាលពីខែមករា ឆ្នាំ ២០២៥។ វីដេអូនៃការបាក់រលំអគារមួយនៅក្នុងប្រទេសថៃ ដែលកើតចេញពីគ្រោះរញ្ជួយដីកាលពីខែមីនា ឆ្នាំ ២០២៥ ក៏ត្រូវបានគេយកមកបង្ហាញខុសពីការពិតថាជាលទ្ធផលនៃជម្លោះផងដែរ។

ឫសគល់នៃព័ត៌មានមិនគួរឱ្យទុកចិត្តច្រើនលើសលុបបែបនេះ និងការយល់ច្រឡំនៃអង្គហេតុអាចបណ្តាលមកពីរយ៉ាង៖ ទីមួយ គឺអវត្តមាននៃបណ្តាញព័ត៌មានគួរឱ្យទុកចិត្ត និងការផ្តល់ព័ត៌មានឱ្យទាន់ពេលពីសំណាក់រដ្ឋាភិបាលទៅកាន់ប្រព័ន្ធផ្សព្វផ្សាយ និងទីពីរ គឺការពិតដែលថាមានប្រព័ន្ធផ្សព្វផ្សាយឯករាជ្យតិចតួចប៉ុណ្ណោះដែលនៅសេសសល់ក្នុងប្រទេសកម្ពុជា ដូច្នេះហើយការរាយការណ៍ព័ត៌មានភាគច្រើនគឺចេញពីបណ្តាញផ្សព្វផ្សាយដែលគាំទ្ររដ្ឋាភិបាល មិនបានឃ្លាតឆ្ងាយពីវោហារស័ព្ទផ្លូវការរបស់រដ្ឋាភិបាល ឬមិនត្រួតពិនិត្យនូវ

អ្វីដែលលើកឡើង។ អ្នកសារព័ត៌មានម្នាក់ដែល ម.ស.ម.ក បានសម្ភាសលើកឡើងថា៖ «ពួកយើងដែលនៅមានឆន្ទៈ និងមានលទ្ធភាពព្យាយាមផ្ទៀងផ្ទាត់ព័ត៌មាន កំពុងតែថយចុះទៅៗ ហើយរឿងនេះកាន់តែពិបាកឡើងៗ ដោយសារតែមានព័ត៌មានជន់ជោរខ្លាំងពេកនៅលើបណ្តាញសង្គម»។ អ្នកសារព័ត៌មានក៏បានសង្កេតឃើញផងដែរនូវខ្លឹមសារអ្នកមានឥទ្ធិពលលើបណ្តាញសង្គម និងបុគ្គលសាធារណៈមានឥទ្ធិពលបានធ្វើឡើង ដែលបានបំពេញចន្លោះប្រហោងរបស់អ្នកសារព័ត៌មាន ហើយដែលមើលទៅហាក់បីដូចជាមានតម្លាភាព និងទទួលបានព័ត៌មាន។ ការស្រាវជ្រាវលើទម្លាប់នៃការតាមដានព័ត៌មាន ចំណង់ចំណូលចិត្តប្រព័ន្ធផ្សព្វផ្សាយ និងកម្រិតនៃការជឿទុកចិត្តរបស់ប្រជាពលរដ្ឋកម្ពុជា ដែលត្រូវបានបោះពុម្ពផ្សាយកាលពីដើមឆ្នាំនេះ បានបង្ហាញថា សូម្បីតែមុនពេលមានជម្លោះ ក៏មានការមិនពេញចិត្តរួចទៅហើយទាក់ទងនឹងការរាយការណ៍ព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងឥទ្ធិពលនៃផលប្រយោជន៍នយោបាយ និងពាណិជ្ជកម្ម ព្រមទាំងកង្វល់លើព័ត៌មានមិនពិតនិងព័ត៌មានក្លែងក្លាយ។[5]

អារម្មណ៍នៃការមិនពេញចិត្តគួរឱ្យកត់សម្គាល់ក្នុងចំណោមសាធារណជន អំពីការយល់ឃើញថាមានភាពលំអៀងក្នុងការរាយការណ៍ព័ត៌មាននៃជម្លោះនេះក៏កើតមានផងដែរ ដោយសារតែអត្ថបទសំណេរជាច្រើនរបស់បណ្តាញផ្សព្វផ្សាយព័ត៌មានអន្តរជាតិត្រូវបានរាយការណ៍ចេញពីការិយាល័យរបស់បណ្តាញទាំងនោះ ដែលមានមូលដ្ឋាននៅទីក្រុងបាងកក។ ដូចដែលអ្នកសារព័ត៌មានម្នាក់បានចង្អុលបង្ហាញ ទីក្រុងភ្នំពេញធ្លាប់ជាមជ្ឈមណ្ឌលសម្រាប់បណ្តាញផ្សព្វផ្សាយព័ត៌មានអន្តរជាតិកាលពីមួយទសវត្សរ៍មុនប៉ុណ្ណោះ ប៉ុន្តែប៉ុន្មានឆ្នាំចុងក្រោយនេះ បណ្តាញទាំងនោះបានផ្លាស់ប្តូរទីតាំងទៅកាន់ប្រទេសថៃកាន់តែច្រើនឡើងៗ ដោយសារតែលំហសម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននៅក្នុងប្រទេសកម្ពុជាកាន់តែរួមតូចទៅៗ។ អ្នកសារព័ត៌មានដែលគ្មានអង្គភាពមួយចំនួនបានកត់សម្គាល់ថា បណ្តាញផ្សព្វផ្សាយព័ត៌មានអន្តរជាតិដែលពួកគេធ្លាប់បានផ្តល់សេចក្តីរាយការណ៍ មិនបានទាក់ទងជាមួយពួកគេដើម្បីចេញផ្សាយរបាយការណ៍អំពីជម្លោះ ដោយពួកគេបានលើកឡើងនូវមូលហេតុមួយចំនួនដូចជា៖ កត្តារាំងស្ទះផ្នែកថវិកា ចំណូលពីការផ្សាយពាណិជ្ជកម្ម កង្វះចំណាប់អារម្មណ៍អន្តរជាតិលើជម្លោះក្នុងតំបន់ ដោយសារជម្លោះផ្សេងទៀតដែលកំពុងកើតឡើងនៅជុំវិញពិភពលោកកំពុងគ្របដណ្តប់លើប្រព័ន្ធផ្សព្វផ្សាយមួយនេះ។ ទោះបីជាយ៉ាងណាក៏ដោយ កង្វះខាតការចូលរួមពីបណ្តាញផ្សព្វផ្សាយព័ត៌មានអន្តរជាតិ គឺជាប្រភពនៃភាពតានតឹងសម្រាប់អ្នកសារព័ត៌មានទាំងនោះ។

## សេចក្តីសន្និដ្ឋាន

បទពិសោធន៍របស់អ្នកសារព័ត៌មានទាំងនេះ ជាពិសេសអារម្មណ៍នៃការមិនមានសន្តិសុខដែលពួកគេបានទទួល ការព្រួយបារម្ភរបស់ពួកគេអំពីអ្វីដែលពួកគេអាច និងមិនអាចបោះពុម្ពផ្សាយបាន និងសេចក្តីរាយការណ៍របស់ពួកគេអាចត្រូវបានអាជ្ញាធរចាត់ទុកថាខុស រួមទាំងភាពតានតឹងរបស់ពួកគេទាក់ទងនឹងការរីករាល

[5] គាំទ្រប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ(IMS), លើពីបន្ទប់សារព័ត៌មាន: ទស្សនៈរបស់ទស្សនិកជនលើប្រព័ន្ធផ្សព្វផ្សាយកម្ពុជា, (ខែកក្កដា ឆ្នាំ២០២៥)។

ដាលនៃព័ត៌មានក្លែងក្លាយ ក្នុងលក្ខខណ្ឌដែលគ្មានព័ត៌មានគួរឱ្យទុកចិត្ត មិនមែនជាបញ្ហា តែមួយក្នុងបរិបទជម្លោះរវាងកម្ពុជា-ថៃនោះទេ ប៉ុន្តែជាងនេះទៅទៀតគឺជាការធ្វើឱ្យស្ថានភាពកាន់តែអាក្រក់ឡើងៗ នៃលក្ខខណ្ឌដែលមានស្រាប់សម្រាប់បណ្តាញផ្សព្វផ្សាយព័ត៌មានឯករាជ្យ និងអ្នកសារព័ត៌មាននៅកម្ពុជាបច្ចុប្បន្នទៅវិញ។

ជាក់ស្តែង មានករណីមួយចំនួនដែលព័ត៌មាន និងការណែនាំច្បាស់លាស់ពីអាជ្ញាធរអំពីតំបន់ ឬទីកន្លែងដែលការចូលទៅត្រូវបានហាមឃាត់សម្រាប់គោលបំណងយោធា អាចជួយសម្រួលដល់ការរាយការណ៍ព័ត៌មានដែលមិនបានធ្វើឱ្យប៉ះពាល់ដល់គោលដៅយោធារបស់កម្ពុជា និងកាត់បន្ថយហានិភ័យសម្រាប់អ្នកសារព័ត៌មាន។ នៅក្នុងករណីផ្សេងទៀត ការឆ្លើយតបរបស់រដ្ឋាភិបាល អាចត្រូវបានចាត់ទុកថាមិនសមាមាត្រ និងជាការរឹតត្បិតលើអ្នកសារព័ត៌មានដែលជារឿងមិនចាំបាច់ និងទំនងជាផ្អែកលើហេតុផលលាក់កំបាំងដើម្បីគ្រប់គ្រងការបកស្រាយ ឬការយល់ឃើញរបស់សាធារណជនអំពីជម្លោះ។

និយាយជារួម បទពិសោធន៍របស់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលរាយការណ៍លើជម្លោះនេះ គឺជាការឆ្លុះបញ្ចាំងតូចមួយនៃទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយក្នុងប្រទេសកម្ពុជាទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលខុសប្លែកពីគេនោះ គឺការមិនពេញចិត្តរបស់សាធារណជនជុំវិញការរីករាលដាលនៃព័ត៌មានក្លែងក្លាយនៅលើបណ្តាញសង្គម។[6] ការជន់ជោរនៃព័ត៌មានដែលមិនបានផ្ទៀងផ្ទាត់នៅលើបណ្តាញសង្គម និងអសមត្ថភាពរបស់បុគ្គល និងស្ថាប័នសារព័ត៌មានក្នុងការត្រួតពិនិត្យលើការបកស្រាយរបស់រដ្ឋាភិបាលដោយភ័យខ្លាចពីការចោទប្រកាន់ព្រហ្មទណ្ឌ បានបង្ហាញអំពីផលវិបាកនៃការបាត់បង់នូវប្រព័ន្ធផ្សព្វផ្សាយឯករាជ្យរបស់ប្រទេសមួយនេះ។ ទោះជាយ៉ាងណាក៏ដោយ ការលាតត្រដាងបែបនេះអាចដើរតួជាចំណុចបត់មួយផ្សេងទៀត។ រដ្ឋាភិបាលគួរតែឆ្លៀតឱកាសនេះដើម្បីបើកលំហសេរីភាពប្រព័ន្ធផ្សព្វផ្សាយ និងអាចឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យដំណើរការនៅក្នុងប្រទេស ពីព្រោះតួនាទីដ៏សំខាន់របស់ប្រព័ន្ធផ្សព្វផ្សាយនៅក្នុងសង្គម ត្រូវបានបង្ហាញឱ្យឃើញកាន់តែច្បាស់នៅក្នុងបរិបទនៃជម្លោះនេះ ហើយតម្រូវការរបស់សាធារណជនសម្រាប់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យមិនគួរព្រងើយកន្តើយនោះទេ។

## អនុសាសន៍ជូនរាជរដ្ឋាភិបាលកម្ពុជា

- បើកឱ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ដែលមានស្រាប់ និងមានសក្តានុពល ដើម្បីដំណើរការក្នុងប្រទេសកម្ពុជាដោយមិនមានការជ្រៀតជ្រែក ឬដាក់សម្ពាធលើសកម្មភាពស្របច្បាប់របស់ពួកគេ។
- ចាត់វិធានការប្រកបដោយប្រសិទ្ធភាពដើម្បីធានានូវការចេញបណ្ណសម្គាល់អ្នកសារព័ត៌មានទាន់ពេលវេលាដល់អ្នកសារព័ត៌មាន រួមទាំងអ្នកសារព័ត៌មានដែលគ្មានអង្គភាព និងដោយគ្មានការរើសអើងដោយផ្អែកលើប្រព័ន្ធផ្សព្វផ្សាយដែលពួកគេធ្វើការ តួនាទីរបស់ពួកគេជាអ្នកសារព័ត៌មានដែលគ្មានអង្គភាព ឬការជាប់

[6] ឌី ឌីផ្លូមាត (The Diplomat), ហេតុអ្វីបានជាប្រទេសកម្ពុជាចាញ់សង្គ្រាមព័ត៌មានជាមួយប្រទេសថៃ, ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥។ ខេមបូចា, ជម្លោះកម្ពុជា និងថៃស្ងប់ស្ងាត់ តែការប្រយុទ្ធលើបណ្តាញសង្គមនៅបន្ត, ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៥។

ទាក់ទង ឬការយល់ឃើញរបស់ពួកគេ ឬការមិនជាប់ទាក់ទងនោះ។ ជាផ្នែកមួយនៃវិធានការប្រកបដោយប្រសិទ្ធភាពទាំងនេះ សូមលុបបំបាត់តម្រូវការ និងសំណួរដែលមិនចាំបាច់ក្នុងដំណើរការធ្វើបណ្ណសម្គាល់អ្នកសារព័ត៌មាន រួមទាំងមុខតំណែងពីមុនរបស់ពួកគេផងដែរ ដោយសារប្រព័ន្ធចុះបញ្ជីអ្នកសារព័ត៌មានត្រូវបានបង្កើតឡើងដើម្បីជួយសម្រួលជាជាងកំហិតសេរីភាពសារព័ត៌មាន។

- ផ្តល់ព័ត៌មានទាន់ពេលវេលានិងត្រឹមត្រូវដល់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ដោយមិនប្រកាន់ពីសម្ព័ន្ធភាពនិងសាធារណជនទាក់ទងនឹងជម្លោះបច្ចុប្បន្ន ហើយអនុម័តការអនុវត្តនេះជាទម្លាប់ដ៏ល្អបំផុតសម្រាប់ពេលអនាគត។
- ផ្តល់ឱ្យប្រព័ន្ធផ្សព្វផ្សាយនូវបញ្ជីទំនាក់ទំនងនៃមន្ត្រីបង្គោលរបស់រដ្ឋាភិបាលពាក់ព័ន្ធ ក្នុងអំឡុងពេលមានជម្លោះ ឬភាពចលាចល ស្រដៀងនឹងអ្វីដែលបានផ្តល់ជូនក្នុងអំឡុងពេលបោះឆ្នោត ដើម្បីជួយសម្រួលដល់ការផ្តល់ព័ត៌មានដល់ប្រព័ន្ធផ្សព្វផ្សាយ និងអាចឱ្យអ្នកសារព័ត៌មានផ្ទៀងផ្ទាត់ព័ត៌មាន។
- សូមជានាការឆ្លើយតបទៅនឹងសំណើសុំព័ត៌មានពីអ្នកសារព័ត៌មាន និងបណ្តាញផ្សព្វផ្សាយឱ្យបានទាន់ពេលវេលានិងឱ្យអស់លទ្ធភាព ក្នុងអំឡុងពេលមានជម្លោះនិងភាពចលាចល ដើម្បីជួយសម្រួលដល់ការរាយការណ៍ព័ត៌មានឱ្យបានច្បាស់លាស់និងត្រឹមត្រូវ សម្រាប់ជាផលប្រយោជន៍សាធារណៈ។

សម្រាប់ព័ត៌មានបន្ថែម សូមផ្ញើអ៊ីម៉ែលទៅកាន់ ម.ស.ម.ក តាមរយៈ៖ info@cchrcambodia.org ឬទូរស័ព្ទលេខ ៖ +៨៥៥ ២៣ ៧២ ៦៩ ០១។

-----ចប់-----

ខែវិច្ឆិកា ឆ្នាំ២០២៥

CC BY NC SA